# សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី
# បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ សិក្ខាសាលាផ្សព្វផ្សាយឯកសារគោល
# នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧-២០១៨




(រាជធានីភ្នំពេញ)៖ ព្រឹកថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងមហាផ្ទៃ មានបើកសិក្ខាសាលាផ្សព្វផ្សាយឯកសារគោល នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី** មានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង លោក លោកស្រី មកពីក្រសួង ស្ថាប័ន និងបណ្តារាជធានី-ខេត្ត ព្រមទាំងអង្គការដៃគូពាក់ព័ន្ធមួយចំនួនផងដែរ។

នៅក្នុងអង្គសិក្ខាសាលា **សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី** មានប្រសាសន៍សង្កត់ធ្ងន់ទៅលើបញ្ហាចំនួនបីចំណុច ដែលត្រូវរួមគ្នាអនុវត្តក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖



១.អំពីបញ្ហាបិទច្រករបៀងតាមព្រំដែន ជាពិសេសតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រសួងមហាផ្ទៃ ក៏ដូចជាអគ្គស្នងការនគរបាលជាតិ ធ្លាប់បានណែនាំអំពីការបិទច្រករបៀងទាំងអស់តាមព្រំដែនកម្ពុជា ជាមួយប្រទេសជាប់ព្រំដែន ព្រោះវាជាច្រកដែលអាចប្រព្រឹត្តបទល្មើស រត់ពន្ធទំនិញគ្រប់ប្រភេទដោយមិនមានបង់ពន្ធ ក៏ដូចជារត់ពន្ធមនុស្សជាដើម។ ឥឡូវមានការសំណូមពរពីប្រជាពលរដ្ឋដែលរស់នៅខេត្តជាប់ព្រំដែនថា ឲ្យបើកច្រករបៀងឡើងវិញ ដើម្បីឲ្យពួកគាត់បានធ្វើការឆ្លងកាត់ចេញ-ចូល រកស៊ីលើទឹកដីថៃ ក្នុងការដោះស្រាយជីវភាពពីព្រោះពួកគាត់ចូលព្រឹក ត្រឡប់មកវិញពេលល្ងាច។ សម្តេចបានឲ្យក្រុមការងារកិច្ចការច្រកទ្វារព្រំដែន នៃក្រសួងមហាផ្ទៃដឹកនាំដោយ **ឯកឧត្តម ឌុល គឿន** ត្រូវធ្វើការសិក្សាស្រាវជ្រាវឲ្យបានច្បាស់លាស់អំពីច្រករបៀងនៅតាមព្រំដែន ជាពិសេសព្រំដែនកម្ពុជា-ថៃ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវសហការក្នុងការងារនេះ ថាយើងត្រូវបិទឬបើក ស្វែងរកគុណសម្បត្តិ និងគុណវិបត្តិ នៃការបើក និងបិទច្រករបៀង ដើម្បីធ្វើការដោះស្រាយឲ្យទាន់ពេលវេលា តាមការស្នើសុំរបស់ប្រជាពលរដ្ឋ។

២.អំពីអាជ្ញាធរថៃ ចាប់បញ្ជូនពលករខ្មែរត្រឡប់មកវិញទាំងខុសច្បាប់ និងស្របច្បាប់ មានចំនួនពី១០០នាក់ទៅ២០០នាក់ក្នុង១ថ្ងៃ ស្ថិតក្នុងស្ថានភាពបែបនេះសូមឲ្យអាជ្ញាធរយើងរកវិធីដោះស្រាយឲ្យបានឆាប់រហ័ស ឲ្យថៃជួយផ្តល់ព័ត៌មានដែលត្រូវបញ្ជូនពលករខ្មែរត្រឡប់មកវិញ បើយើងមិនដឹងមិនលឺ គេថារដ្ឋាភិបាលយើងមិនទទួលខុសត្រូវចំពោះពលរដ្ឋយើង ត្រូវបង្កលក្ខណៈងាយស្រួលដល់ពួកគាត់ ហើយអាជ្ញាធរយើងក៏ងាយស្រួលក្នុងការសាកសួរព័ត៌មានពីពួកគាត់ ហេតុអ្វីបានគាត់ទៅ? គាត់ទៅធ្វើការងារអ្វី? ម្យ៉ាងទៀតបើមានពលរដ្ឋខ្មែរណាម្នាក់មានគ្រោះថ្នាក់ ឬស្លាប់ អាជ្ញាធរយើងត្រូវធ្វើការស្រាវជ្រាវបន្ទាន់ឲ្យបានច្បាស់លាស់អំពីមូលហេតុដើម្បីដោះស្រាយជាមួយគ្រួសារគាត់នៅស្រុកកំណើត។




៣.យើងត្រូវធ្វើការរៀបចំឯកសារ ក្នុងការចុះអនុស្សរណៈ (MOU) ជាមួយបណ្តាប្រទេសណាដែលមានពលរដ្ឋខ្មែរទៅធ្វើការ និងរស់នៅទីនោះ ដូចជាប្រទេសម៉ាឡេស៊ី យើងមិនទាន់បានធ្វើនៅឡើយទេ។ **សម្តេចបានជម្រុញឲ្យខាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ពន្លឿនពេលវេលា នៃការធ្វើឯកសារនានាក៏ដូចជាលិខិតឆ្លងដែនជូនប្រជាពលរដ្ឋ ជាពិសេសពលរដ្ឋខ្មែរដែលធ្វើការនៅប្រទេសថៃ ដើម្បីកុំឲ្យពួកគាត់ជួបនូវបញ្ហាផ្សេងៗ ពេលដែលគាត់កំពុងធ្វើការនៅទីនោះ។ សម្តេច** សូមឲ្យឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ធ្វើការណែនាំដល់ខាងតុលាការពង្រឹងការកាត់ក្តីបទល្មើសជួញដូរមនុស្សឲ្យបានតឹងរឹង ក៏ដូចជាបទល្មើសគ្រឿងញៀនដែលសព្វថ្ងៃរដ្ឋាភិបាលយើងកំពុងរួមគ្នាយកចិត្តទុកដាក់ទប់ស្កាត់ និងមានវិធានការធ្ងន់ធ្ងរចំពោះជនល្មើសដែលបានជួញដូរ និងប្រើប្រាស់។




តាមរយៈការផ្តល់បទសម្ភាសន៍ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអ**ចិន្ត្រៃយ៍ គ.ជ.ប.ជ** បានបញ្ជាក់ឲ្យដឹងថា៖ សព្វថ្ងៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាប្រទេសនានាកំពុងតែជួបប្រទះនូវបញ្ហាជួញដូរមនុស្ស ជួញដូរផ្លូវភេទលើស្ត្រី និងកុមារ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ដែលជាបញ្ហាមួយដ៏ធ្ងន់ធ្ងរសម្រាប់មនុស្សជាតិទាំងមូល ហើយបញ្ហាទាំងនេះក៏បានលេចឡើងនូវរូបភាពថ្មីៗផងដែរ ដែលយើងត្រូវរួបរួមសហការគ្នារិះរកវិធានការថ្មីៗ ដើម្បីធ្វើការទប់ស្កាត់បទល្មើសទាំងអស់នេះអោយទាន់ពេលវេលា។



លោកជំទាវបានបន្ថែមថា រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាបាន និងកំពុងរៀបចំឯកសារក្នុងការចុះអនុស្សរណៈ (MOU) ជាមួយបណ្តាប្រទេសនៅក្នុងតំបន់អាស៊ាន ក៏ដូចជាប្រទេសនានា និងអង្គការអន្តរជាតិមួយចំនួនផងដែរដើម្បីចូលរួម ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាន **សម្តេចក្រឡាហោម ស ខេង** ជាប្រធាន បាននិងកំពុងសហការជាមួយបណ្តាក្រសួងស្ថាប័ន អង្គការជាតិ អន្តរជាតិពាក់ព័ន្ធ និងមានរចនាសម្ព័ន្ធការងារពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ ដើម្បីបំពេញការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យមានប្រសិទ្ធភាពខ្ពស់។ **លោកជំទាវបញ្ជាក់ថា** ការរៀបចំឯកសារគោល នៃផែនការសកម្មភាពជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ មានគោលដៅលើកកម្ពស់ការងារ ដើម្បីលុបបំបាត់ និងទប់ស្កាត់រាល់ទម្រង់ជួញដូរមនុស្សគ្រប់រូបភាព ដូចជាការជួញដូរផ្លូវភេទលើស្ត្រី និងកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការទប់ស្កាត់លំហូរឆ្លងកាត់ព្រំ

ដែនខុសច្បាប់ ជាពិសេសការធ្វើចំណាកស្រុករបស់ពលរដ្ឋខ្មែរទៅធ្វើការនៅប្រទេសថៃ ដែលតែងតែមានបញ្ហា ហើយត្រូវបានអាជ្ញាធរថៃ ចាប់បញ្ជូនមកវិញរៀងរាល់ថ្ងៃមានចំនួនពី១០០នាក់ ទៅ២០០នាក់ **(នេះជាបញ្ហាសម្រាប់រាជរដ្ឋាភិបាលកម្ពុជា)**។

















**រូបភាពពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**